# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


០៤-១០-២០១២ - ព្រះរាជក្រឹត្យ នស/រកត/១០១២/៩០៣ ស្តីពី ការកែសម្រួលឋានន្តរស័ក្តិ លោក **សុខ ហេង** ពីឋានន្តរស័ក្តិ វររមន្ត្រីថ្នាក់លេខ ៨ ទៅក្នុងឋានន្តរស័ក្តិ ឧត្តមមន្ត្រីថ្នាក់លេខ ៥ ជាករណីពិសេស នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ៧៦៦៣

០៦-១០-២០១២ - ព្រះរាជក្រឹត្យ នស/រកត/១០១២/៩០៤ ស្តីពី ការតម្លើងថ្នាក់ ប្រចាំឆ្នាំ ជូនមន្ត្រីរាជការ ចំនួន ២១ រូប ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួង ស្ថាប័ន និង មន្ត្រីការទូតជាន់ខ្ពស់ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការ អន្តរជាតិ ៧៦៦៤

០៦-១០-២០១២ - ព្រះរាជក្រឹត្យ នស/រកត/១០១២/៩០៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ថ្នាក់ដឹកនាំ និង មន្ត្រីរាជការ ចំនួន ៣៨ រូប ៧៦៦៧

០៦-១០-២០១២ - ព្រះរាជក្រឹត្យ នស/រកត/១០១២/៩០៦ ស្តីពី ការផ្ទេរបញ្ចូលមន្ត្រីរាជការ ចំនួន ០២ រូប ទៅក្នុងឋានន្តរស័ក្តិ អនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ៧៦៦៩

០៦-១០-២០១២ - ព្រះរាជក្រឹត្យ នស/រកត/១០១២/៩០៧ ស្តីពី ការផ្ទេរបញ្ចូលមន្ត្រីរាជការ ចំនួន ០២ រូប ទៅក្នុងឋានន្តរស័ក្តិ អនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ៧៦៧០

០៦-១០-២០១២ - ព្រះរាជក្រឹត្យ នស/រកត/១០១២/៩០៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ទីប្រឹក្សា នាយករងខុទ្ទកាល័យ ជំនួយការពិធីការ និង សមាជិកក្រុមលេខា នៃខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចំនួន ៦៥ រូប ៧៦៧១

០៦-១០-២០១២ - ព្រះរាជក្រឹត្យ នស/រកត/១០១២/៩០៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ មន្ត្រីរាជការ នៃក្រសួងផែនការ ចំនួន ០៨ រូប ៧៦៧៣

០៦-១០-២០១២ - ព្រះរាជក្រឹត្យ នស/រកត/១០១២/៩១០ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ទោ ជូនលោកឧត្តមសេនីយ៍ត្រី **ហែម ថេង** នាយនគរបាលជាតិ នៃក្រសួងមហាផ្ទៃ ៧៦៧៤

០៦-១០-២០១២ - ព្រះរាជក្រឹត្យ នស/រកត/១០១២/៩១១ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ទោ ជូនលោកឧត្តមសេនីយ៍ត្រី **ឆែន ប៉ូរ៉ានី** នាយនគរបាលជាតិ នៃក្រសួងមហាផ្ទៃ ៧៦៧៥

០៦-១០-២០១២ - ព្រះរាជក្រឹត្យ នស/រកត/១០១២/៩១២ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ទោ ជូនលោកឧត្តមសេនីយ៍ត្រី **ស្ងួន ផល្លី** នាយនគរបាលជាតិ នៃក្រសួងមហាផ្ទៃ ៧៦៧៦

០៦-១០-២០១២ - ព្រះរាជក្រឹត្យ នស/រកត/១០១២/៩១៣ ស្តីពី ការកែសម្រួលឋានន្តរស័ក្តិ លោក **ថន ថា** ពីនាយលេខាធិការរដ្ឋបាលថ្នាក់លេខ ១ ទៅអនុមន្ត្រីថ្នាក់លេខ ១៤ នៃ ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលជាករណីពិសេស នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ៧៦៧៧

០៩-១០-២០១២ - ព្រះរាជក្រឹត្យ នស/រកត/១០១២/៩១៤ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ជូនមន្ត្រីរាជការ ចំនួន ១០ រូប ពីវរមន្ត្រី ទៅឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួង ស្ថាប័ន ៧៦៧៨

០៩-១០-២០១២ - ព្រះរាជក្រឹត្យ នស/រកត/១០១២/៩១៦ ស្តីពី ការផ្ទេរបញ្ចូលលោក **ឆូ ទិប្ពុល** ទៅក្នុងឋានន្តរស័ក្តិ អនុមន្ត្រីថ្នាក់លេខ ៦ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ៧៦៨០

## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ

០៤-១០-២០១២ - អនុក្រឹត្យលេខ ១៦៩ អនក្រ.បក ស្តីពី ការកាត់ចេញពីផែនទីគម្របព្រៃឈើ ឆ្នាំ ២០០២ និង ក្រុមហ៊ុនព្រៃសម្បទាន សាមលីញ ធ្វើអនុបយោគមកជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីសរុបចំនួន ១.៤៩១ ហិកតា នៅភូមិដូនមាស ឃុំគោកស្រុក ស្រុកតំបែរ ខេត្តកំពង់ចាម និង ធ្វើប្រទានកម្ម ជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និង ដាំដុះជាក់ស្តែង ៧៦៨១

០៤-១០-២០១២ - អនុក្រឹត្យលេខ ១៧០ អនក្រ.បក ស្តីពី ការកាត់ចេញពីគម្របព្រៃឈើ ឆ្នាំ ២០០២ ពីដីសម្បទាន សេដ្ឋកិច្ចក្រុមហ៊ុនភាពីម៉ិច និង ធ្វើអនុបយោគមកជាដីឯកជន របស់រដ្ឋ នូវផ្ទៃដីទំហំ ៣.៤៩៥ ហិកតា នៅឃុំពេជចង្វារ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង និង ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១.១៧៨ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និង ដាំដុះជាក់ស្តែង ៧៦៨៤

០៨-១០-២០១២ -អនុក្រឹត្យលេខ ១៧១ អនក្រ.បក ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិគ្រប់គ្រង និង អភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ៧៦៨៧

០១-១០-២០១២ -អនុក្រឹត្យលេខ ១៣១៣ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៧៦៩៦

០១-១០-២០១២ -អនុក្រឹត្យលេខ **១៣៣៣** ដល់អនុក្រឹត្យលេខ **១៣៥៣** អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៧៦៩៧

០២-១០-២០១២ -អនុក្រឹត្យលេខ ១៣៥៤ អនក្រ.តត ស្តីពី ការដំឡើងឋានន្តរស័ក្តិ និង ការផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីក្រមការ មន្ត្រីរាជការ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច ៧៧១៨

០២-១០-២០១២ -អនុក្រឹត្យលេខ ១៣៥៥ អនក្រ.តត ស្តីពី ការដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការ ៧៧២១

០២-១០-២០១២ -អនុក្រឹត្យលេខ **១៣៥៦** ដល់អនុក្រឹត្យលេខ **១៣៨២** អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៧៧២៣

## ២-សារាចរ

១៦-១០-២០១២ -សារាចរលេខ ០១ សរ ស្តីពី ការផ្អាកការប្រារព្ធពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និង អកអំបុក ឆ្នាំ ២០១២ នៅរាជធានីភ្នំពេញ ៧៧៥០

## ៣-សារាចរណែនាំ

១៥-១០-២០១២ -សារាចរណែនាំលេខ ១១ សរណន ស្តីពី ការចូលរួមគោរពព្រះវិញ្ញាណក្ខន្ធព្រះបរមសពព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និង ឯកភាពជាតិខ្មែរ ៧៧៥២

## ៤-សេចក្តីណែនាំ

០៥-១០-២០១២ -សេចក្តីណែនាំរបស់រាជរដ្ឋាភិបាលលេខ ០៣ សណន ស្តីពី ការត្រៀមវិធានការទុកជាមុនចំពោះព្យុះហ្គាអេមី " GAEMI " ៧៧៥៤

# III-ការងារបណ្តាក្រសួង

## ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៤-៦-២០១១ -លិខិតបញ្ជាក់លេខ ៣៣០៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្គោលដេន ងាសែល** ៧៧៥៦

១៤-៦-២០១១ -លិខិតបញ្ជាក់លេខ ៣៣១០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **តេសិ តេព ចាវ្យ គ្រុប** ៧៧៥៨

១៤-៦-២០១១ -លិខិតបញ្ជាក់លេខ ៣៣១២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ការិយាល័យតំណាងពាណិជ្ជកម្មក្រុមហ៊ុន **យូ-ចាង ផ្លេន អេនជីនារីង & ខនស្ត្រាក់សិន** ៧៧៦០

១៥-៦-២០១១ -លិខិតបញ្ជាក់លេខ ៣៣១៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សេដេន ថាយហ្វើរ** ៧៧៦១

១៥-៦-២០១១ -លិខិតបញ្ជាក់លេខ ៣៣២៤ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការកែប្រែ និង តម្កល់ទុកលក្ខន្តិកៈថ្មី របស់ក្រុមហ៊ុន **អ៊ី គី អ៊ីមផត អិចផត ត្រេឌីង ខប** ៧៧៦៣

១៥-៦-២០១១ -លិខិតបញ្ជាក់លេខ ៣៣៣២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្គោលដេន ប្លូសហ្វ៊ីម** ៧៧៦៥

១៥-៦-២០១១ -លិខិតបញ្ជាក់លេខ ៣៣៣៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្គោលដេន ផេតឌី** ៧៧៦៧

១៦-៦-២០១១ -លិខិតបញ្ជាក់លេខ ៣៣៦៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **តាបោន អ៊ិនវេសមេន (ខេមបូឌា)** ៧៧៦៩

១៦-៦-២០១១ -លិខិតបញ្ជាក់លេខ ៣៣៦៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឡាយស្ទ្រីង អ៊ិនហ្វូមីធីត** ៧៧៧១

១៧-៦-២០១១ -លិខិតបញ្ជាក់លេខ ៣៣៧២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្គោលដេន ស្តុត** ៧៧៧៣

១៧-៦-២០១១ -លិខិតបញ្ជាក់លេខ ៣៣៨៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ិតស្ទ្រីម 3 ឌី & ខនស្ត្រាក់សិន** ៧៧៧៥

១៧-៦-២០១១ -លិខិតបញ្ជាក់លេខ ៣៣៨៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស្រ្តី សៃ អេហ្វ្រី បាយអូ អ៊ិនវេសមេន (ខេមបូឌា)** ៧៧៧៧

# ព្រះរាជក្រឹត្យ

## យើង

នស/រកត/១០១២/៩០៧

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** កែសម្រួលឋានន្តរសក្តិ លោក សុង ហេង ពីឋានន្តរសក្តិវរមន្ត្រីថ្នាក់លេខ ៨ ទៅក្នុងឋានន្តរសក្តិឧត្តមមន្ត្រីថ្នាក់លេខ ៥ ជាករណីពិសេស នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
**នរោត្តម សីហមុនី**

៧រល. ១៤១០.៩១៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១២

លេខៈ ៨៦៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ១៧ ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី
... សុខា

# ព្រះរាជក្រឹត្យ

នស/រកត/១០១២/៩០៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការប្រឆាំងអំពើពុករលួយ
-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីការទូតជាន់ខ្ពស់
-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

**ត្រាស់បង្គាប់**

**មាត្រា១** : ដំឡើងថ្នាក់ប្រចាំឆ្នាំជូនមន្ត្រីរាជការចំនួន ១៥ រូប ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួង ស្ថាប័ន ៖

**ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**

| ល.រ | នាម និងគោត្តនាម | ភេទ | ឋានន្តរស័ក្តិ និងថ្នាក់ចាស់ | ឋានន្តរស័ក្តិ និងថ្នាក់ត្រូវដំឡើង |
|---|---|---|---|---|
| ១ | **ឱក សុផុន** | ប | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៣ |

**ក្រសួងទេសចរណ៍**

| ល.រ | នាម និងគោត្តនាម | ភេទ | ឋានន្តរស័ក្តិ និងថ្នាក់ចាស់ | ឋានន្តរស័ក្តិ និងថ្នាក់ត្រូវដំឡើង |
|---|---|---|---|---|
| ១ | **គោស៊ុំ សារឿត** | ប | ពីឧត្តមមន្ត្រី ថ្នាក់លេខ ២ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ១ |

**ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

| ល.រ | នាម និងគោត្តនាម | ភេទ | ឋានន្តរស័ក្តិ និងថ្នាក់ចាស់ | ឋានន្តរស័ក្តិ និងថ្នាក់ត្រូវដំឡើង |
|---|---|---|---|---|
| ១ | **ភោគ សុវណ្ណរិទ្ធ** | ប | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៣ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ២ |
| ២ | **គីម ទូច** | ប | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៣ |
| ៣ | **សុខ ឡេង** | ប | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៣ |

**ក្រសួងផែនការ**

| ល.រ | នាម និងគោត្តនាម | ភេទ | ឋានន្តរស័ក្តិ និងថ្នាក់ចាស់ | ឋានន្តរស័ក្តិ និងថ្នាក់ត្រូវដំឡើង |
|---|---|---|---|---|
| ១ | **អ៊ិន សារឿង** | ប | ពីឧត្តមមន្ត្រី ថ្នាក់លេខ ២ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ១ |
| ២ | **វង្ស សាម៉ុន** | ប | ពីឧត្តមមន្ត្រី ថ្នាក់លេខ ២ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ១ |
| ៣ | **នុត ច័ន្ទសុខា** | ប | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៣ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ២ |
| ៤ | **សេង សឿន** | ប | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៣ |
| ៥ | **បូ សុភាព** | ប | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៣ |
| ៦ | **ម៉ម ម៉ារ៉ាឌី** | ប | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៤ |
| ៧ | **ឡូន ផាវរៈ** | ប | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៥ |

**អង្គភាពប្រឆាំងអំពើពុករលួយ**

| ល.រ | នាម និងគោត្តនាម | ភេទ | ឋានន្តរស័ក្តិ និងថ្នាក់ចាស់ | ឋានន្តរស័ក្តិ និងថ្នាក់ត្រូវដំឡើង |
|---|---|---|---|---|
| ១ | **ឆាយ សាឌុន** | ប | ពីឧត្តមមន្ត្រី ថ្នាក់លេខ ២ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ១ |

**រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ**

| ល.រ | នាម និងគោត្តនាម | ភេទ | ឋានន្តរស័ក្តិ និងថ្នាក់ចាស់ | ឋានន្តរស័ក្តិ និងថ្នាក់ត្រូវដំឡើង |
|---|---|---|---|---|
| ១ | **តាន់ ឌុន្ណា** | ប | ពីឧត្តមមន្ត្រី ថ្នាក់លេខ ២ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ១ |
| ២ | **ចៅ សេដ្ឋាណា** | ប | ពីឧត្តមមន្ត្រី ថ្នាក់លេខ ២ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ១ |

**មាត្រា២**: ដំឡើងថ្នាក់ប្រចាំឆ្នាំជូនមន្ត្រីរាជការចំនួន ០៦ រូប ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រីការបរទេស នៃក្របខណ្ឌមន្ត្រីការទូតជាន់ខ្ពស់ ចាប់ពីថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១២ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ៖

**ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

| ល.រ | នាម និងគោត្តនាម | ភេទ | ឋានន្តរស័ក្តិ និងថ្នាក់ចាស់ | ឋានន្តរស័ក្តិ និងថ្នាក់ត្រូវដំឡើង |
|---|---|---|---|---|
| ១ | **មាស គឹមហេង** | ប | ពីឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ ២ | ទៅឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ១ |

| | | | | |
|---|---|---|---|---|
| ២ | **អ៊ឹម សុភីរ** | ប | ពីឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ ៤ | ទៅឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ៣ |
| ៣ | **ឌុយ រី** | ប | ពីឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ ៤ | ទៅឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ៣ |
| ៤ | **ហោ មុនីរ័ត្ន** | ប | ពីឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ ៥ | ទៅឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ៤ |
| ៥ | **ហុង បញ្ញារិទ្ធ** | ប | ពីឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ ៥ | ទៅឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ៤ |
| ៦ | **ថៃ ទណ្ណា** | ប | ពីឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ ៥ | ទៅឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ៤ |

**មាត្រា៣**: បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤**: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា៥**: ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស.រកត.១០១២.៩១៤

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១២*

លេខ:៨៧៩ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ២០១២
**អគ្គលេខាធិការរងនៃរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១០១២/៩០៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

ចំពោះ

ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ចំនួន៣៨រូប នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ លើវិស័យគ្រប់គ្រងគ្រោះមហន្តរាយ កន្លងមក

នូវ

**ក-គ្រឿងឥស្សរិយយស ជាតូបការ**

-ឯកឧត្តម **ហង្ស សាមឿន**

**ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍**

| | | | | | |
|---|---|---|---|---|---|
| ១-ឯកឧត្តម | **ឡាំ** | **ហេងហួត** | ២-លោក | **ម៉ែន** | **សំអន** |

**គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា**

| | | | | | |
|---|---|---|---|---|---|
| ១-ឯកឧត្តម | **គីម** | **វឌ្ឍានា** | ២-ឯកឧត្តម | **រស់** | **សុវណ្ណ** |

**ឃ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា**

| | | | | | |
|---|---|---|---|---|---|
| ១-ឯកឧត្តម | **កែវ** | **វី** | ៥-លោក | **អ៊ូ** | **ចាន់ឌី** |
| ២-ឯកឧត្តម | **សៀក** | **វិចិត្រ** | ៦-លោក | **ជួប** | **ស៊ីថន** |
| ៣-ឯកឧត្តម | **ញឹក** | **ប៊ុនរិទ្ធ** | ៧-លោក | **អែម** | **ហុង** |
| ៤-ឧកញ៉ា | **ហេង** | **ឱុយ** | ៨-លោក | **ជា** | **ប្រណិត** |

**ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ**

| | | | | | |
|---|---|---|---|---|---|
| ១-លោក | **ម៉ី** | **មគ្គ** | ៨-លោក | **សុទ្ធ** | **សឺន** |
| ២-លោក | **សុខ** | **លូ** | ៩-លោក | **ផាន់** | **ចាន់ថុល** |
| ៣-លោក | **កែម** | **សុធឿន** | ១០-លោក | **ជឹម** | **សារ៉េន** |
| ៤-លោកស្រី | **គង់** | **ស៊ីថា** | ១១-លោក | **យស** | **ណាស៊ី** |
| ៥-លោក | **ឈុំ** | **វណ្ណារិទ្ធ** | ១២-លោក | **អោម** | **ចន្ថា** |
| ៦-ឯកឧត្តម | **អេង** | **ប៊ុនហ៊ាង** | ១៣-លោក | **អ៊ុំធឿន** | **គុណាវុឌ្ឍ** |
| ៧-ឯកឧត្តម | **ចាន់** | **យឿន** | ១៤-លោក | **ខូយ** | **រីដា** |

ROYAUME DU CAMBODGE
LE MINISTRE ... PALAIS ROYAL

**ច-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា**

| | | | | | |
|---|---|---|---|---|---|
| ១-ឯកឧត្តម | **ម៉ា** | **នរិទ្ធ** | ៥-លោក | **ខឹម** | **ច័ន្ទគីរី** |
| ២-ឯកឧត្តម | **ឃុន** | **សុខា** | ៦-លោក | **ពៅ** | **សុភាព** |
| ៣-លោក | **ឃួន** | **យា** | ៧-លោក | **គឹម** | **សារម៉េត** |
| ៤-លោកស្រី | **ម៉ុន** | **វណ្ណាឌី** | ៨-វេជ្ជបណ្ឌិត | **ច័ន្ទ** | **សុខា** |

**ឆ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ**

| | | | | | |
|---|---|---|---|---|---|
| ១-លោក | **ចយ** | **ភាព** | ៣-លោក | **គុណា** | **វីរៈ** |
| ២-លោក | **អ៊ឹម** | **សុផល** | | | |

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣៧៥-១៥១០-៩១៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែតុលា ឆ្នាំ២០១២

លេខៈ ៨៧៨ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២

**អគ្គលេខាធិការ[illegible]រាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១០១២/៩០៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្ទេរបញ្ចូលមន្ត្រីរាជការចំនួន ០២រូប ទៅក្នុងឋានន្តរស័ក្តិ អនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ :

| ល.រ | នាមត្រកូល និងនាមខ្លួន | ឋានន្តរស័ក្តិ ថ្នាក់ចាស់ | ឋានន្តរស័ក្តិ ថ្នាក់ថ្មី |
|---|---|---|---|
| ១ | លោក **អ៊ាន ណារម្យ** | នាយក្រមការ ថ្នាក់លេខ ៣ | អនុមន្ត្រី ថ្នាក់លេខ ៨ |
| ២ | លោក **គង់ គីមនី** | អនុសេនីយ៍ទោ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ | អនុមន្ត្រី ថ្នាក់លេខ ១៣។ |

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៣៧.១៤១០.៩០៦

សេ.ជ.ព្រ.៧០ ច.ល
...រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ចក
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែ៧ ឆ្នាំ២០១២
...ទីស្តីការគណៈរដ្ឋមន្ត្រី ទីស្តីការរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១២

សុយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/១០១២/៩០៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្ទេរបញ្ចូលមន្ត្រីរាជការចំនួន ០២រូប ទៅក្នុងឋានន្តរស័ក្តិ អនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ :

| ល.រ | នាមត្រកូល និងនាមខ្លួន | ឋានន្តរស័ក្តិ ថ្នាក់ចាស់ | ឋានន្តរស័ក្តិ ថ្នាក់ថ្មី |
|---|---|---|---|
| ១ | លោក **ម៉ា សាវឿត** | នាយក្រមការ ថ្នាក់លេខ ៥ | អនុមន្ត្រី ថ្នាក់លេខ ១២ |
| ២ | លោក **ខួន ឡាញ់** | នាយក្រមការ ថ្នាក់លេខ ៦ | អនុមន្ត្រី ថ្នាក់លេខ ១៤ ។ |

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧.១៤១០.៩០៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១២

លេខ [illegible] ច.ល
ដើម្បីចម្លងចែកជូន
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១២
[illegible] ស្ដីការគណៈរដ្ឋមន្ត្រី
[illegible] សុខា

# ព្រះរាជក្រឹត្យ

នស/រកត/១០១២/៩០៨

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ទីប្រឹក្សា នាយករងខុទ្ទកាល័យ ជំនួយការ ពិធីការនិងសមាជិកក្រុមលេខានៃខុទ្ទកាល័យ
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចំនួន៦៩រូប
មានគុណបំណាច់និងស្នាដៃល្អជាច្រើនក្នុងការបំរើជាតិមាតុភូមិ តាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល

## នូវ

### ក-គ្រឿងឥស្សរិយយស ជាតូបការ

| | | | | | |
|---|---|---|---|---|---|
| ១-ឯកឧត្តម | ស្រី | ថាវរុទ្ធ | ៤-ឯកឧត្តម | ហ៊ុន | ស៊ីថា |
| ២-ឯកឧត្តម | ប៊ុន | សំបូរ | ៥-ឯកឧត្តម | លឹម | លាងសែ |
| ៣-ឯកឧត្តម | ធ្លាក់ | ចន្ទទី | ៦-លោកជំទាវ | សុខឡេង | ឫរ៉ា |

### ខ-គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រិយានី ព្រះស៊ីសុវត្ថិមុនីវង្ស កុសុមៈនារីរ័ត្ន ថ្នាក់ មហាសេរីវឌ្ឍន៍

| | | | | | |
|---|---|---|---|---|---|
| ១-ឯកឧត្តម | នុត | ឈឿម | ៣-ឯកឧត្តម | សូរ | គីមអាន |
| ២-ឯកឧត្តម | យុន | ឈី | ៤-ឯកឧត្តម | សេង | ឡៀង |

### គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍

| | | | | | |
|---|---|---|---|---|---|
| ១-ឯកឧត្តម | កង | កេង | ៤-ឯកឧត្តម | សាមីឌី | ស៊ីឡូនា |
| ២-ឯកឧត្តម | ញៀម | សូភឿន | ៥-ឯកឧត្តម | រស់ | កុសល |
| ៣-ឯកឧត្តម | មិន | ចណ្ឌីណាធុង | ៦-ឯកឧត្តម | តាន់ | បញ្ញាធុង |

### ឃ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍

| | | | | | |
|---|---|---|---|---|---|
| ១-ឯកឧត្តម | អ៊ុក | ចាន់ | ៦-ឯកឧត្តម | ធ្លាក់ | សោភ័ណ |
| ២-ឯកឧត្តម | ហ៊ុន | ហេង | ៧-លោកជំទាវ | ធ្វី | សុខា |
| ៣-ឯកឧត្តម | ជុំ | កុសល | ៨-ឯកឧត្តម | ជា | យុពា |
| ៤-ឯកឧត្តម | ចួន | ស្រេង | ៩-លោកជំទាវ | រស់ | ចំនួនល្អី |
| ៥-ឯកឧត្តម | សុខ | សូរិយា | | | |

### ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា

| | | | | | |
|---|---|---|---|---|---|
| ១-ឯកឧត្តម | ខាំពូន | កែវមុនី | ៥-ឯកឧត្តម | ប៊ុន | ណោ |
| ២-ឯកឧត្តម | នុត | បូពិណ្ណារ៉ា | ៦-ឯកឧត្តម | ជាវ | សាទី |
| ៣-ឯកឧត្តម | រាល | ម៉ារ៉ាទី | ៧-ឯកឧត្តម | ហូ | មនោ |
| ៤-ឯកឧត្តម | ស្លាត | សុភាព | ៨-ឯកឧត្តម | ហាក់ | សុខហៃ |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

| | | | | | |
|---|---|---|---|---|---|
| ៩-ឯកឧត្តម | ខួន | សំណាង | ១៣-ឯកឧត្តម | ជា | សារឿន |
| ១០-ឯកឧត្តម | គាំ | សុខុន | ១៤-ឯកឧត្តម | ឈន | ប៉េងឡេង |
| ១១-ឯកឧត្តម | អៀង | សិរីវង្ស | ១៥-ឯកឧត្តម | ហ៊ុន | ម៉ានិត |
| ១២-ឯកឧត្តម | សោម | សុខុឌ្ឍី | | | |

ច-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

| | | | | | |
|---|---|---|---|---|---|
| ១-ឯកឧត្តម | ឈរ | ផល្លី | ៣-ឯកឧត្តម | សំ | ខណ្ឌារ៉ា |
| ២-ឯកឧត្តម | ឱ | ពៅ | ៤-លោកជំទាវ | ម៉ែន | នារីសោភ័គ |

ឆ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ

| | | | | | |
|---|---|---|---|---|---|
| ១-លោកជំទាវ | ញៀម | ស៊ីណាត | ១១-ឯកឧត្តម | នី | ប៊ុនលី |
| ២-ឯកឧត្តម | ឈួន | គឹមឆយ | ១២-ឯកឧត្តម | ឆេង | ស៊ីថា |
| ៣-ឯកឧត្តម | អ៊ុក | ណារ៉ា | ១៣-ឯកឧត្តម | មាស | វិបុល |
| ៤-លោកជំទាវ | មាស | វិចិត្រ | ១៤-ឯកឧត្តម | សុខ | វីរៈ |
| ៥-លោកជំទាវ | ប៉ក់សម៉យ | សុវិឌ្ឍានី | ១៥-ឯកឧត្តម | លី | ត្រាណរិន |
| ៦-លោកជំទាវ | ម៉ាន់ | ចរិយា | ១៦-ឯកឧត្តម | សុខ | យន |
| ៧-លោកជំទាវ | ឈរ | ស្រីពីង | ១៧-ឯកឧត្តម | សូ | ខនបញ្ញារិទ្ធិ |
| ៨-លោកជំទាវ | គង់ | ម៉ារីយ៉ | ១៨-ឯកឧត្តម | ហេង | សុខណាង |
| ៩-លោកជំទាវ | អ៊ាន | អមរា | ១៩-ឯកឧត្តម | ហ៊ុន | ម៉ានី |
| ១០-លោកជំទាវ | ឆេង | សុជារី | | | |

ជ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា

| | | | | | |
|---|---|---|---|---|---|
| ១-ឯកឧត្តម | កែវ | ចាន្ធី | ២-ឯកឧត្តម | ចាន់ | សុខុម |

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៧៧-១៥១០-៩១៨

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១២

លេខៈ ៨៧៥ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០១២

អគ្គលេខាធិការរងអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/១០១២/៩០៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

មន្ត្រីរាជការ នៃក្រសួងផែនការ ចំនួន០៨រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ

នូវ

ក-គ្រឿងឥស្សរិយយស ជាតូបការ :
ឯកឧត្តម អ៊ូ ឱហាត

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :
ឯកឧត្តម ឆួន ថាវរៈ

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :
១-ឯកឧត្តម តៀក សារិន
២-លោក ជា ចាន់ធុំ

ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :
១-លោកស្រី ជូ ពុទ្ធានី
២-លោក ស៊ិន សេដ្ឋា
៣-លោក ឆាយ សត្យា

ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :
លោក វ៉ែត រុងរក្សា

ព្រះហស្ថលេខា និងព្រះរាជលញ្ចករ
នរោត្តម សីហមុនី

៣៧.១៤១០.៩១៩

លេខ:៤៧៥០.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែ តុលា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការរដ្ឋាភិបាល
[illegible] សុខា

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១២

# ព្រះរាជក្រឹត្យ

នស/រកត/១០១២/៩១០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : ដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ទោ** ជូនលោកឧត្តមសេនីយ៍ត្រី **ហែម ថេង** អត្តលេខ ០៨៣៨ នាយនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុក អនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ ៩១៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ១០ ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល
[illegible] សុខា

៣៧៨-១៥១០-៩៤០

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១២*

# ព្រះរាជក្រឹត្យ

នស/រកត/១០១២/៩១១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ទោ** ជូនលោកឧត្តមសេនីយ៍ត្រី **ទែន ម៉ូរ៉ានី** អត្តលេខ ០២០៩ នាយនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុក អនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៣៧-១៤១០-៩៤១

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១២
អគ្គលេខាធិការរាជរដ្ឋាភិបាល

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១២*

# ព្រះរាជក្រឹត្យ

នស/រកត/១០១២/៩១៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្រុមខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ទោ** ជូនលោកឧត្តមសេនីយ៍ត្រី **សួន ផល្លី** អត្តលេខ ០៣៣៤៧ នាយនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុក អនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ: ៤៧២ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១២
អគ្គលេខាធិការ [illegible] រដ្ឋាភិបាល
[illegible] សុខា

៣កស-១៤១០-៩៤៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១២

# ព្រះរាជក្រឹត្យ

នស/រកត/១០១២/៩៦៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** កែសម្រួលឋានន្តរសក្តិ **លោក ចន ថា** ពីនាយលេខាធិការរដ្ឋបាល ថ្នាក់លេខ ១ ទៅ**អនុមន្ត្រី** ថ្នាក់លេខ១៤ នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ជាករណីពិសេស នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧៤-១៤១០-៩៤៣

លេខ [illegible] ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១២
អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល
[illegible] ស៊ុយ សុខា

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១២*

# ព្រះរាជក្រឹត្យ

នស/រកត/១០១២/៩១៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពុហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១:** ដំឡើងឋានន្តរស័ក្តិជូនមន្ត្រីរាជការចំនួន ១០ រូប ពីវរមន្ត្រី ទៅឧត្តមមន្ត្រី នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួង ស្ថាប័ន ៖

| ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | | | | |
|---|---|---|---|---|
| ល.រ | នាមនិងគោត្តនាម | ភេទ | ឋានន្តរស័ក្តិ និងថ្នាក់ចាស់ | ឋានន្តរស័ក្តិ និងថ្នាក់ត្រូវដំឡើង |
| ១ | ឌុន ឈ៉ាន | ប | ពីវរមន្ត្រី ថ្នាក់លេខ ២ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៤ |

ROYAUME DU CAMBODGE
ព្រះបរមរាជវាំង
LE MINISTRE DU PALAIS ROYAL

| | | | | |
|---|---|---|---|---|
| ២ | **សាត សាមី** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៣ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៤ |
| ៣ | **សាត សមុទ្រ** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៣ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៤ |
| **ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | | | | |
| ល.រ | នាម និងគោត្តនាម | ភេទ | ឋានន្តរស័ក្តិ និងថ្នាក់ចាស់ | ឋានន្តរស័ក្តិ និងថ្នាក់ត្រូវដំឡើង |
| ១ | **សាន ចណ្ណធី** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៧ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ២ | **ឡោ រស្មី** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៣ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៤ |
| ៣ | **សៅ សំបូរ** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៣ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៤ |
| ៤ | **ថៅ ប៊ុនថាន** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៦ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| **ក្រសួងបរិស្ថាន** | | | | |
| ល.រ | នាម និងគោត្តនាម | ភេទ | ឋានន្តរស័ក្តិ និងថ្នាក់ចាស់ | ឋានន្តរស័ក្តិ និងថ្នាក់ត្រូវដំឡើង |
| ១ | **ម៉េង សាខុន** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៥ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៥ |
| ២ | **ជឹម រដ្ឋា** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៧ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| **ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | | | | |
| ល.រ | នាម និងគោត្តនាម | ភេទ | ឋានន្តរស័ក្តិ និងថ្នាក់ចាស់ | ឋានន្តរស័ក្តិ និងថ្នាក់ត្រូវដំឡើង |
| ១ | **ឯក ធីរៈដេជ្ជ** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៧ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៦ |

**មាត្រា២:** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣:** សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា៤:** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

[illegible] ១២១០.៩២៤

*ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១២*

លេខៈ៨៨៩ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ .ថ្ងៃទី ១៧ [illegible] ឆ្នាំ២០១២
**អគ្គលេខា[illegible]រដ្ឋាភិបាល**

**[illegible] ខុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១០១២/៩១៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី២២ ខែ កុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែ ឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្ទេរបញ្ចូលលោក **ឌូ ទិមុល** ទៅក្នុងឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៦ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៧រលា.១២១០.៩២៦

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១២

លេខ ៩៤៥ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ១០ ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល

**ស៊យ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ១៦៩.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ចេញពីផែនទីគម្របព្រៃឈើឆ្នាំ២០០២ និងក្រុមហ៊ុនព្រៃសម្បទាន សាមលីញ ធ្វើអនុបយោគ មកជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីសរុបចំនួន ១,៤៩១ ហិកតា នៅភូមិ ដូនមាស ឃុំ គោកស្រុក ស្រុក តំបែរ ខេត្ត កំពង់ចាម និងធ្វើប្រទានកម្មជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨អនក្រ.បកចុះថ្ងៃទី០១ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ០២ សរ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការប្រឡូងប្រឆាំងកែលំអសោភ័ណភាពខេត្តទូទាំងប្រទេស
- បានឃើញសារាចរលេខ ០៥ សរ ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០០ របស់រាជរដ្ឋាភិបាលស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- តាមសំណើលេខ ១៩២៦ លខ កច ចុះថ្ងៃទី១០ ខែ កញ្ញា ឆ្នាំ ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាម
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ចេញពីផែនទីគម្របព្រៃឈើឆ្នាំ២០០២ និងក្រុមហ៊ុនព្រៃសម្បទាន សាមលីញ និងធ្វើអនុបយោគមកជាដីឯកជនរបស់រដ្ឋ នូវចំណែកផ្ទៃដីសរុប ១,៤៩១ហិកតា (មួយពាន់បួនរយកៅសិបមួយហិកតា) នៅភូមិ ដូនមាស ឃុំ គោកស្រុក ស្រុក តំបែរ ខេត្ត កំពង់ចាម ដែលក្នុងនោះកាត់ដីចេញពី ដីគម្របព្រៃឈើឆ្នាំ២០០២ ទំហំ **៥៣៦ ហិកតា** ពីក្រុមហ៊ុនព្រៃសម្បទាន សាមលីញ ចំនួន **៩៥៥ ហិកតា** តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាម ដើម្បីធ្វើការគ្រប់គ្រងនិងប្រទានកម្មដោយផ្តល់នូវសិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង ភូមិ ដូនមាស ឃុំ គោកស្រុក ស្រុក តំបែរ ខេត្ត កំពង់ចាម ជូនប្រជាពលរដ្ឋចំនួន ១០៧៦ (មួយពាន់ចិតសិបប្រាំមួយ) គ្រួសារ

**មាត្រា ៣ ..**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាម ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងសង្គមនៅក្នុងមូលដ្ឋាន។

**មាត្រា ៤ ..**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល ៖*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៧៤០ . អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុនភាពីម៉ិច និងធ្វើអនុបយោគមកជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ៣ ៤៩៥ ហិកតា នៅឃុំពេជចង្វារ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង និងធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១ ១៧៨ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨អនក្រ.បកចុះថ្ងៃទី០១ខែធ្នូ ឆ្នាំ២០០០ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ០២ សរ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការប្រឡងប្រណាំងកែលំអសោភ័ណភាពខេត្តទូទាំងប្រទេស
- បានឃើញសារាចរលេខ ០៥ សរ ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០០ របស់រាជរដ្ឋាភិបាលស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ៥៤០ លស ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ឆ្នាំង
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ចេញនិងធ្វើអនុបយោគមកជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីសរុបទំហំ ៣៤៩៥ហិកតា (បីពាន់បួនរយកៅសិបប្រាំហិកតា) ដែលក្នុងនោះកាត់ចេញពីដែនទីគម្របព្រៃឈើឆ្នាំ២០០២ នូវផ្ទៃដីទំហំ ២៩១ ហិកតា និងពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុនភាពីម៉ិច ( លិខិតលេខ ៨៥២ សជណ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី) នូវផ្ទៃដីទំហំ ៣២០៤ ហិកតា មានទីតាំងស្ថិតនៅឃុំពេជចង្វារ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ឆ្នាំង ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិតាំងធ្នឹម ចំនួន ២៩៦ គ្រួសារ ភូមិតាំងត្រពាំង ចំនួន ២៩៦ គ្រួសារ ភូមិថ្នល់ចំនួន ១៩៨ គ្រួសារ ភូមិក្រាំងកកោះ ចំនួន ១៩៧ គ្រួសារ និងភូមិទឹកជ្រាប ចំនួន ៩១ គ្រួសារ ។

**មាត្រា ៣ .-**

ក្នុងពេលដំណើរការវាស់វែងនិងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ឆ្នាំង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។/

**មាត្រា ៤ .-**

